ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ២២៩ ឧស ២០១៧

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួល និងបំពេញបន្ថែមការកំណត់ថ្លៃលក់ទឹកស្អាត ដែលផលិត និងផ្គត់ផ្គង់ដោយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ១៥៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ៤៦១ MIH/2014 ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និង សិប្បកម្ម ស្តីពីនីតិវិធីសម្រាប់ការចេញ កែសម្រួល បន្ត ព្យួរ និងដកហូតប្រកាស អនុញ្ញាតឲ្យធ្វើ អាជីវកម្ម ផ្គត់ផ្គង់ ទឹកស្អាត
- បានឃើញប្រកាសលេខ ១៤៦ MIH/២០១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម និង សិប្បកម្ម ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍រួមនៃការកំណត់ថ្លៃលក់ទឹកស្អាត
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**ប្រការ១.-**

ត្រូវបានកែសម្រួល និងបំពេញបន្ថែមការកំណត់ថ្លៃលក់ទឹកស្អាត ដែលផលិត និងផ្គត់ផ្គង់ដោយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សម្រាប់លក់ជូនដល់ម្ចាស់ផ្ទះ ឬម្ចាស់អគារដែលមានបន្ទប់ជួលឱ្យកម្មករ កម្មការិនី និងសិស្ស និស្សិត ស្នាក់នៅ ដោយគិតក្នុងតម្លៃ ៧០០៛ (ប្រាំពីររយរៀល) ក្នុងមួយម៉ែត្រគូប។

**ប្រការ២.-**

ម្ចាស់ផ្ទះ ឬម្ចាស់អគារដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវលក់ទឹកស្អាតជូនដល់កម្មករ កម្មការិនី និងសិស្ស និស្សិត ក្នុងតម្លៃ ៨០០៛ (ប្រាំបីរយរៀល) ក្នុងមួយម៉ែត្រគូប។

**ប្រការ៣.-**

ការកែសម្រួល និងបំពេញបន្ថែមការកំណត់ថ្លៃលក់ទឹកស្អាតដូចមានចែងក្នុងប្រការ១ និងប្រការ២ ខាងលើនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ តទៅ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ, ខេត្តកណ្តាល គ្រប់អង្គភាពពាក់ព័ន្ធ និងម្ចាស់ផ្ទះ ឬ ម្ចាស់អគារ ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧

**ជ. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋមន្ត្រីស្តីទី**

**សាត សាមី**

**__កន្លែងទទួល__ ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានីភ្នំពេញ
- រដ្ឋបាលខេត្តកណ្តាល

*«ដើម្បីជូនជ្រាប»*

- អគ្គនាយកដ្ឋានទឹកស្អាត
- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ, ខេត្តកណ្តាល
- ដូចប្រការ៥

*«ដើម្បីអនុវត្តមុខការ»*

- ឯកសារ-កាលប្បវត្តិ